**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៣០/០០២/២០០៧

ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ២០០៧

**សេចក្តីសម្រេច**

លេខ : ០៩០/០០១/២០០៧ កបធ.ច

ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ០០២ រស ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦ របស់ឯកឧត្តម ខួន ញឿង ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ ហើយព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ ដោយឯកភាពទាំងស្រុងតាមទម្រង់ និង គតិនៃអត្ថបទច្បាប់នេះ ដោយឥតកែប្រែក្នុងសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ២ នីតិកាលទី ២ នាថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៦ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៧ វេលាម៉ោង ១៥:៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុង មាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- យល់ឃើញថា សំណើរបស់ឯកឧត្តម **ខួន ញឹម** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី២នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៦នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨
- យល់ឃើញថា ទម្រង់នៃការតាក់តែងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិក្នុងមាត្រានីមួយៗនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ មិនមានចំណុចណាដែលអាចចាត់ទុកថា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ ហើយព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ដោយឯកភាពទាំងស្រុងតាមទម្រង់ និង គតិនៃអត្ថបទច្បាប់នេះ ដោយឥតកែប្រែក្នុងសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ២ នីតិកាលទី ២ នាថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៦ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៧

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន